# ខ្លឹមសារសង្ខេបសាលដីការបស់តុលាការកំពូលប្រទេសអាហ្វ្រិកខាងត្បូង

**Supreme Court of South Africa, *Public Prosecutor v. Staden,* Case No: 730/2011**

**28 November 2012**

**<u>ពាក្យគន្លឹះ៖</u>** ដីកាបង្កកទ្រព្យ, កាតព្វកិច្ចបញ្ចេញភស្តុតាង (disclosure), កម្រិតនៃភស្តុតាង (standard of proof)

## ១. ប្រវត្តិនីតិវិធី

លោក Staden ជាប្រធានក្រុមហ៊ុន ដែលមានបុគ្គលិកមួយចំនួន ដូចជា De Vries។ Staden ត្រូវបានចោទពីបទឆោកបោក (fraud) រងនូវការស៊ើបអង្កេត ហើយ de Vries ជាសាក្សីមួយ ដែលបានធ្វើសេចក្តីថ្លែងការណ៍ដាក់បន្ទុក។ រដ្ឋអាជ្ញា បានស្នើទៅសាលាដំបូង រារាំងជនជាប់ចោទ មិនឲ្យប្រើប្រាស់ទ្រព្យដែលបានមកពីអំពើឆបោក (provisional restraint order)។ សាលដំបូង បានឯកភាពតាមសំណើរបស់រដ្ឋអាជ្ញា។ លោក Staden បានប្តឹងឧទ្ធហរណ៍ ហើយសាលាឧទ្ធរណ៍បានឯកភាព លុបចេញនូវដីកា។ រដ្ឋអាជ្ញា បានប្តឹងសាទុក្ខទៅតុលាការកំពូល ប្រឆាំងនឹងការសម្រេចនេះ។

## ២. វិធានអនុវត្ត

ដើម្បីសម្រេចចេញដីកា ឬ រក្សាដីកា វិធានទាមទារថា៖ *វាទំនងជាមានមូលដ្ឋានសមស្របដែលអាចសន្និដ្ឋានថា មានទោសពៃរ៍ និងមានដីការឹបអូស* (កថា. ១០)។ បន្ថែមពីលើនេះ រដ្ឋអាជ្ញា ត្រូវដាក់ភស្តុតាងថា ទ្រព្យស្ថិតក្រោមដីកានោះ ជារបស់ជនជាប់ចោទ  ហើយការបង្ហាញនេះ ក្នុងកម្រិតភស្តុតាង probability។ ដីកានេះ នឹងត្រូវបានលុបចោល ប្រសិនបើជនត្រូវចោទ មិនត្រូវបានចោទប្រកាន់។

## ៣. សម្អាងហេតុ និងខ្លឹមសារសម្រេច

រដ្ឋអាជ្ញា បានបញ្ចេញឯកសាររួចហើយ ដើម្បីគាំទ្រការចេញដីកានេះ លើកលែង សេចក្តីថ្លែងការណ៍ជាសំឡេងរបស់ de Vries ដែលប្រសិនបើបញ្ចេញទៅ អាចប៉ះដល់គាត់ ដែលទាមទាររក្សាការសម្ងាត់។ រដ្ឋអាជ្ញា បានថតជាសំឡេងដាក់ក្នុង CD ទោះបីមិនមានដាក់ index សម្រាប់ការស្រាវជ្រាវក្តីដល់ចៅក្រម ដែលលោក Staden ក៏អាចទទួលបានដែរ។ បន្ថែមពីលើនេះ រដ្ឋអាជ្ញាថា នឹងបង្ហាញនូវសេចក្តីថ្លែងនោះ ក្នុងពេលសវនាការ។ ការណ៍នេះ មានន័យថា រដ្ឋអាជ្ញា បានធ្វើការងារដោយសុទ្ធចិត្ត។

ជនជាប់ចោទ មិនបានបដិសេធនូវការប្រព្រឹត្តដូចចោទទេ ហើយ ទ្រព្យជាកម្មវត្ថុនៃការបង្អក ក៏ជារបស់ក្រុមហ៊ុនរបស់គាត់ដែរ។ ផ្អែកតាមអង្គហេតុនេះ ថៅក្រមបានសម្រេចថា៖ ដីការបស់សាលាឧទ្ធរណ៍ត្រូវបានបដិសេធ និងជំនួសដោយដីកានេះ ក្នុងខ្លឹមសារថា៖ *ដីកាចេញក្នុងថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៨ ត្រូវតែរក្សាទុក* (តុលាការជាន់ទាប)។ *ចុងចម្លើយ ត្រូវចេញនូវចំណាយ នៃការដាក់ពាក្យសុំ និងថ្លៃសេវាមេធាវី*។

**សម្រាប់អត្ថបទនៃសេចក្ដីសម្រេចទាំងស្រុងសូមចូលទៅកាន់គេហទំព័រ៖**

http://www.measboralaws.com/images/pdf/verdict/fdcdd6b4edcf345500809aa21667e71e.pdf